**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៨.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការស្នើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើត **គណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល** ដែលសរសេរជាអក្សរកាត់ "គ.ជ.ប្រ.ថ." ជាសេនាធិការជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារប្រសិទ្ធភាពថាមពលនៅព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

# ជំពូកទី២
# តួនាទី និងភារកិច្ច

**មាត្រា២ .-**

គ.ជ.ប្រ.ថ. មានតួនាទី និងភារកិច្ច ដូចខាងក្រោមៈ

**១- ដឹកនាំ សម្របសម្រួល និងណែនាំការអនុវត្តការងារប្រសិទ្ធភាពថាមពលទាំងមូល**

- កំណត់គោលដៅរួម និងគោលដៅជាក់លាក់សម្រាប់ជំរុញការអនុវត្តការងារប្រសិទ្ធភាពថាមពល
- ផ្តល់ការណែនាំទាំងបច្ចេកទេស និងទាំងទិសដៅការងារ លើគ្រប់ទិដ្ឋភាពដែលទាក់ទងនឹងការផ្តើមគំនិត ការអភិវឌ្ឍ និងការអនុវត្តគម្រោងប្រសិទ្ធភាពថាមពល
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល និង
- សម្របសម្រួលការអនុវត្តគម្រោងជំនួយបច្ចេកទេសទាំងអស់ ដែលគាំទ្រដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ទាក់ទងនឹងការងារប្រសិទ្ធភាពថាមពល។

**២- ត្រួតពិនិត្យ ណែនាំ ការរៀបចំបទដ្ឋាន និងបទប្បញ្ញត្តិបច្ចេកទេស**

- ត្រួតពិនិត្យ និងណែនាំលើការរៀបចំលិខិតបទដ្ឋានបច្ចេកទេស និងសំណើអនុម័តបទដ្ឋានបច្ចេកទេសសម្រាប់ការអនុវត្ត និងជំរុញការងារប្រសិទ្ធភាពថាមពល
- ពិនិត្យ និងផ្តល់អនុសាសន៍លើការកំណត់លិខិតបទដ្ឋានគតិយុត្តសម្រាប់ការកំណត់អត្តសញ្ញាណ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" ដែលត្រូវធ្វើការគ្រប់គ្រង និងលើកកម្ពស់ប្រសិទ្ធភាពថាមពល តាមវិស័យនៃការប្រើប្រាស់ថាមពលនីមួយៗ
- ផ្តល់អនុសាសន៍ ត្រួតពិនិត្យ និងណែនាំ ក្នុងការរៀបចំបង្កើតបទដ្ឋានគុណផលនៃការប្រើប្រាស់ថាមពល បទដ្ឋាននៃការធ្វើតេស្ត សម្រាប់គ្រប់គ្រងប្រសិទ្ធភាពថាមពលនៃបរិក្ខារប្រើប្រាស់ថាមពល និង
- រៀបចំបង្កើតវិធីសាស្ត្រ មធ្យោបាយ និងនីតិវិធី សម្រាប់ការត្រួតពិនិត្យ អនុលោមភាពនៃបទដ្ឋានដែលបានបង្កើតទាំងនេះ។

**៣- ត្រួតពិនិត្យ និងណែនាំ ការរៀបចំ និងការផ្សព្វផ្សាយចំណេះដឹងប្រសិទ្ធភាពថាមពល**

- ផ្តល់អនុសាសន៍ ត្រួតពិនិត្យ និងណែនាំលើការងារពង្រឹងការយល់ដឹងជាសាធារណៈអំពីអត្ថប្រយោជន៍នៃប្រសិទ្ធភាពថាមពល
- លើកកម្ពស់ការស្រាវជ្រាវ ការអភិវឌ្ឍ និងការបង្កើតគម្រោងសាកល្បង សម្រាប់បច្ចេកវិទ្យាប្រសិទ្ធភាពថាមពលថ្មីៗ និងកំពុងរីកចម្រើន និង
- ផ្តល់អនុសាសន៍ ត្រួតពិនិត្យ និងណែនាំលើការងាររៀបចំបង្កើតគេហទំព័រឃ្លាំងចំណេះដឹងប្រសិទ្ធភាពថាមពល ដែលជាប្រភពផ្តល់ចំណេះដឹង ទិន្នន័យ ព័ត៌មានផ្សេងៗ ដូចជាឯកសារគោលនយោបាយ និងបទប្បញ្ញត្តិប្រសិទ្ធភាពថាមពលនានា ផែនការសកម្មភាពប្រសិទ្ធភាព

ថាមពលតាមវិស័យ ទិន្នន័យស្ថិតិថាមពល ព្រឹត្តិបត្រសិក្សាប្រសិទ្ធភាពថាមពលមានជាអាទិ៍ ជូនដល់សាធារណជន។

**៤- ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារប្រសិទ្ធភាពថាមពល**

- ផ្តល់អនុសាសន៍ ត្រួតពិនិត្យ និងណែនាំលើការងារបង្កើត "ក្របខ័ណ្ឌវាស់វែងគុណផល" ដើម្បីពិនិត្យឡើងវិញនូវប្រសិទ្ធភាព និងផលប៉ះពាល់នៃការអនុវត្តគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល និងការអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យនៃការប្រើប្រាស់ថាមពល មួយឆ្នាំម្តង និង
- ផ្តល់អនុសាសន៍ ត្រួតពិនិត្យ និងណែនាំលើ របាយការណ៍ថ្នាក់ជាតិ នៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តការងារប្រសិទ្ធភាពថាមពល នៅព្រះរាជាណាចក្រកម្ពុជា។

**៥- ការអនុវត្តភារកិច្ចផ្សេងទៀតក្នុងក្របខ័ណ្ឌការងារប្រសិទ្ធភាពថាមពល** តាមការប្រគល់ជូនពីរាជរដ្ឋាភិបាល ឬគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

គ.ជ.ប្រ.ថ. ត្រូវរាយការណ៍ និងស្នើសុំការតម្រង់ទិសជាគោលនយោបាយពី **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។**

## ជំពូកទី៣
## សមាសភាព និងរចនាសម្ព័ន្ធ

**មាត្រា៣.-**

គ.ជ.ប្រ.ថ. មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | ប្រធាន |
| ២- | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- | ប្រធានអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យឧស្សាហកម្ម | អនុប្រធាន |
| ៥- | ប្រធានអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យអគារ | អនុប្រធាន |
| ៦- | ប្រធានអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យសេវាសាធារណៈ និងដឹកជញ្ជូន | អនុប្រធាន |
| ៧- | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ៨- | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១១- | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១២- | តំណាងក្រសួងព័ត៌មាន | សមាជិក |

| | |
|---|---|
| ១៣- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៤- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៥- តំណាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | សមាជិក |
| ១៦- តំណាងអាជ្ញាធរអគ្គិសនីកម្ពុជា | សមាជិក |
| ១៧- តំណាងអគ្គិសនីកម្ពុជា | សមាជិក |
| ១៨- តំណាងអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលរាជធានី-ខេត្ត | សមាជិក |
| ១៩- តំណាងវិស័យឯកជន | សមាជិក។ |

គ.ជ.ប្រ.ថ. អាចមានសមាសភាពបន្ថែម ជារដ្ឋមន្ត្រី ប្រធានស្ថាប័ន ឬតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ គ.ជ.ប្រ.ថ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៤.-**

ដើម្បីដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារប្រសិទ្ធភាពថាមពលទៅតាមវិស័យនៃការប្រើប្រាស់ថាមពលនីមួយៗ គ.ជ.ប្រ.ថ. ត្រូវមានអនុគណៈកម្មាធិការចំនួន ៣ (បី) ដូចខាងក្រោម៖

១- អនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យឧស្សាហកម្ម

២- អនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យអគារ និង

៣- អនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យសេវាសាធារណៈ និងដឹកជញ្ជូន។

បន្ថែមពីលើនោះ ដើម្បីអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពល នៅក្នុងក្របខ័ណ្ឌការងាររបស់រដ្ឋបាលរាជធានី-ខេត្តនីមួយៗ គ.ជ.ប្រ.ថ. ត្រូវមានអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលរាជធានី-ខេត្ត។

អនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលនីមួយៗ ត្រូវបង្កើតក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) ខែ ក្រោយពីកាលបរិច្ឆេទចូលជាធរមាននៃអនុក្រឹត្យនេះ។

គ.ជ.ប្រ.ថ. មានសិទ្ធិបង្កើតអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យផ្សេងទៀត តាមការចាំបាច់នៅពេលក្រោយ។

**មាត្រា៥.-**

អនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យឧស្សាហកម្ម "អ.ប្រ.ថ.ឧ." ត្រូវដឹកនាំដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក.ឧ.វ.ប.ន.) និងមានភារកិច្ចជួយដល់ គ.ជ.ប្រ.ថ. ដូចខាងក្រោម៖

- រៀបចំ និងលើកសំណើផែនការសកម្មភាពប្រសិទ្ធភាពថាមពលសម្រាប់វិស័យឧស្សាហកម្ម
- សិក្សា និងរៀបចំលើកសំណើកម្រិតប្រើប្រាស់ថាមពលអប្បបរមាដើម្បីកំណត់ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" ក្នុងវិស័យឧស្សាហកម្ម

- បង្កើតយន្តការ និងរៀបចំដាក់ឱ្យអនុវត្តការផ្ទើសវនកម្មថាមពលទៀងទាត់លើ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" នៅក្នុងវិស័យឧស្សាហកម្ម
- សិក្សាផ្តួចផ្តើមរៀបចំសំណើគម្រោងប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្ម និង
- តាមរយៈវិទ្យាស្ថានស្តង់ដាកម្ពុជា កំណត់ ឬរៀបចំ និងអនុម័តបទដ្ឋាននៃការធ្វើតេស្តឧបករណ៍ និងបរិក្ខារប្រើប្រាស់ថាមពលសម្រាប់ការអនុវត្តបទប្បញ្ញត្តិបទដ្ឋាន និងការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពល។

ការបង្កើតអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យឧស្សាហកម្ម ត្រូវកំណត់ដោយប្រកាស ឬសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**មាត្រា៦ .-**

អនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យអគារ អ.ប្រ.ថ.អ. ត្រូវដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ក.ដ.ន.ស.) និងមានភារកិច្ចជួយដល់ គ.ជ.ប្រ.ថ. ដូចខាងក្រោម៖

- រៀបចំ និងលើកសំណើផែនការសកម្មភាពប្រសិទ្ធភាពថាមពលសម្រាប់វិស័យអគារ
- សិក្សានិងរៀបចំលើកសំណើកម្រិតប្រើប្រាស់ថាមពលអប្បបរមា ដើម្បីកំណត់ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" នៃវិស័យអគារ
- បង្កើតយន្តការ និងរៀបចំដាក់ឱ្យអនុវត្តការផ្ទើសវនកម្មថាមពលទៀងទាត់លើ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" នៅក្នុងវិស័យអគារ
- រៀបចំបង្កើតវិធានថាមពលសម្រាប់អគារ ដើម្បីគ្រប់គ្រងប្រសិទ្ធភាពថាមពលសម្រាប់ការងារសាងសង់អគារថ្មី ការងារគ្រប់គ្រងអគារ ការងារជួសជុល ការងារកែប្រែ ការងារតម្លើងអគារ ឬការងារកែលម្អអគារមានស្រាប់ និងរៀបចំប្រព័ន្ធត្រួតពិនិត្យ និងពង្រឹងការអនុវត្តការងារទាំងនេះ និង
- កំណត់អត្តសញ្ញាណ និងអភិវឌ្ឍកាលានុវត្តភាពគម្រោង ដោយផ្តោតលើសក្តានុពលនៃការធ្វើឱ្យសម្រេចបានការចំណេញពីប្រសិទ្ធភាពថាមពល ទាំងក្នុងផ្នែកសាងសង់អគារ ទាំងក្នុងផ្នែកកែលម្អអគារ និងទាំងក្នុងផ្នែករៀបចំផែនការនគរូបនីយកម្មរាជធានី ទីក្រុង និងទីប្រជុំជន។

ការបង្កើតអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យអគារ ត្រូវកំណត់ដោយប្រកាស ឬសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៧ .-**

អនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យសេវាសាធារណៈ និងដឹកជញ្ជូន អ.ប្រ.ថ.ស.ដ ត្រូវដឹកនាំដោយក្រសួងសាធារណការ និងដឹកជញ្ជូន (ក.ស.ដ.) និងមានភារកិច្ចជួយដល់ គ.ជ.ប្រ.ថ. ដូចខាងក្រោម៖

- រៀបចំ និងលើកសំណើផែនការសកម្មភាពប្រសិទ្ធភាពថាមពលសម្រាប់វិស័យសេវាសាធារណៈ និងដឹកជញ្ជូន
- សិក្សា និងរៀបចំលើកសំណើកំណត់ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" នៃវិស័យសេវាសាធារណៈ បង្កើតយន្តការ និងរៀបចំដាក់ឱ្យអនុវត្តការធ្វើសវនកម្មថាមពលទៀងទាត់លើ "អ្នកប្រើប្រាស់ថាមពលមុខសញ្ញា" នៅក្នុងវិស័យសេវាសាធារណៈ
- កំណត់អត្តសញ្ញាណ និងអភិវឌ្ឍគម្រោងប្រសិទ្ធភាពថាមពល នៅក្នុងវិស័យសេវាសាធារណៈនិងដឹកជញ្ជូន និង
- ជំរុញ និងលើកកម្ពស់ការអនុវត្តផែនការផ្លាស់ប្តូរពីការប្រើយានយន្តប្រើប្រេងឥន្ធនៈ ទៅជាការប្រើយានយន្តអគ្គិសនី និងសហការជាមួយវិស័យថាមពល នៅក្នុងការជំរុញបង្កើតស្ថានីយបញ្ចូលថាមពលបម្រើឱ្យយានយន្តអគ្គិសនី ដើម្បីគាំទ្រដល់ផែនការប្រើប្រាស់យានយន្តអគ្គិសនីក្នុងវិស័យដឹកជញ្ជូន។

ការបង្កើតអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលវិស័យសេវាសាធារណៈ និងដឹកជញ្ជូន ត្រូវកំណត់ដោយប្រកាស ឬសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា៨ .-**

អនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលរាជធានី-ខេត្ត ត្រូវដឹកនាំដោយរដ្ឋបាលរាជធានី-ខេត្តនីមួយៗ និងមានភារកិច្ចជួយដល់ គ.ជ.ប្រ.ថ. ដូចខាងក្រោម៖

- ដឹកនាំមន្ទីររបស់ក្រសួងពាក់ព័ន្ធនានា ទាំងមន្ទីររបស់ស្ថាប័នបង្គោល និងទាំងមន្ទីររបស់ស្ថាប័នដៃគូ ជំរុញការអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពល នៅក្នុងរាជធានី-ខេត្តរបស់ខ្លួន
- គ្រប់គ្រង សម្របសម្រួល និងជំរុញការអនុវត្តការងារប្រសិទ្ធភាពថាមពលក្នុងក្របខ័ណ្ឌការងាររបស់រដ្ឋបាលរាជធានី-ខេត្ត តាមផែនការសកម្មភាពប្រសិទ្ធភាពថាមពល នៃវិស័យប្រើប្រាស់ថាមពលនីមួយៗ
- បង្កើត និងអនុវត្តគម្រោងប្រសិទ្ធភាពថាមពល ក្នុងក្របខ័ណ្ឌការងាររបស់រដ្ឋបាលរាជធានី-ខេត្ត
- ប្រើប្រាស់សមាជិកអនុគណៈកម្មាធិការមកពីមន្ទីររបស់ស្ថាប័នបង្គោល និងមន្ទីររបស់ស្ថាប័នដៃគូ ដើម្បីប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធ សម្រាប់រាយការណ៍ទៅ គ.ជ.ប្រ.ថ. សម្រាប់ការរៀបចំស្ថិតិថាមពលថ្នាក់ជាតិ និង
- លើកទឹកចិត្តអ្នកប្រើប្រាស់ថាមពលឱ្យចេះសន្សំសំចៃថាមពលដោយរៀបចំយុទ្ធនាការ និងសិក្ខាសាលាពង្រឹង និងពង្រីកការយល់ដឹងអំពីប្រសិទ្ធភាពនៅថ្នាក់រាជធានី-ខេត្ត។

រដ្ឋបាលរាជធានី-ខេត្តនីមួយៗ ត្រូវរៀបចំបង្កើតអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលរាជធានី-ខេត្តរបស់ខ្លួន បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅនៃ គ.ជ.ប្រ.ថ.

### មាត្រា៩ .-

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប្រ.ថ. ត្រូវចូលរួមប្រជុំ ឬចាត់តំណាងមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ។

គ.ជ.ប្រ.ថ. ប្រើប្រាស់ត្រារបស់ក្រសួងរ៉ែនិងថាមពល សម្រាប់ដំណើរការការងារ។

### មាត្រា១០ .-

ប្រធាន គ.ជ.ប្រ.ថ. មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬតំណាងប្រធានស្ថាប័ន ឬអាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ និងបំពេញការងារ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះ។

### មាត្រា១១ .-

គ.ជ.ប្រ.ថ.ព្រមទាំងអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពលមានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬជំនាញការជាតិ និងអន្តរជាតិចូលរួមប្រជុំ ក្នុងឋានៈជាសមាជិក អ្នកសង្កេតការណ៍ ឬអ្នកផ្ដល់យោបល់ តាមការចាំបាច់។

### មាត្រា១២ .-

គ.ជ.ប្រ.ថ. មានអគ្គលេខាធិការដ្ឋានមួយ ជាសេនាធិការសម្រាប់បំពេញមុខងាររបស់ខ្លួន។

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងពីររូប ឬច្រើនរូបតាមការចាំបាច់ ព្រមទាំងមានទីប្រឹក្សា និងអ្នកសិក្សាស្រាវជ្រាវ ជំនួយការអ្នកសិក្សាស្រាវជ្រាវ និងមន្ត្រីមួយចំនួនតាមការចាំបាច់។

អគ្គលេខាធិការ អគ្គលេខាធិការរង និងទីប្រឹក្សា ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។ អ្នកសិក្សាស្រាវជ្រាវ ជំនួយការអ្នកសិក្សាស្រាវជ្រាវ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប្រ.ថ. ត្រូវតែងតាំងដោយអនុក្រឹត្យ ឬប្រកាស អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

### មាត្រា១៣ .-

អគ្គលេខាធិការដ្ឋាននេះ មានភារៈកិច្ចដូចតទៅ៖

- រៀបចំតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា ពាក់ព័ន្ធជាមួយការងារគ្រប់គ្រងប្រសិទ្ធភាពថាមពល
- សហការសម្របសម្រួលជាមួយអនុគណៈកម្មាធិការប្រសិទ្ធភាពថាមពល ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោល-



៩

នយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា ពាក់ព័ន្ធជាមួយការងារគ្រប់គ្រងប្រសិទ្ធភាពថាមពល

- រៀបចំធ្វើកិច្ចការស្រាវជ្រាវ ព្រមទាំងការសម្របសម្រួល និងការរៀបចំកិច្ចពិគ្រោះយោបល់នានាទាំងក្នុងចំណោមស្ថាប័នជាតិ និងជាមួយដៃគូអន្តរជាតិអំពីការងារគ្រប់គ្រងប្រសិទ្ធភាពថាមពលរបស់រាជរដ្ឋាភិបាល
- រៀបចំកិច្ចប្រជុំ គ.ជ.ប្រ.ថ. តាមការណែនាំរបស់ប្រធាន គ.ជ.ប្រ.ថ.
- រៀបចំកំណត់ហេតុអង្គប្រជុំ និងធ្វើសេចក្តីជូនដំណឹងស្តីពីការសម្រេចរបស់រាជរដ្ឋាភិបាលលើសំណើ និងអនុសាសន៍នានារបស់ គ.ជ.ប្រ.ថ. ដល់សមាជិក គ.ជ.ប្រ.ថ. និងស្ថាប័នពាក់ព័ន្ធ
- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ គ.ជ.ប្រ.ថ. តាមការណែនាំ និងការសម្រេចរបស់ប្រធាន គ.ជ.ប្រ.ថ. និងបំពេញការងារផ្សេងៗទៀត តាមការណែនាំរបស់ប្រធាន គ.ជ.ប្រ.ថ.។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា១៤.-**

ប្រភពធនធានសម្រាប់ទ្រទ្រង់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប្រ.ថ. រួមមាន៖

- ថវិកាជាតិប្រចាំឆ្នាំរបស់ក្រសួងរ៉ែ និងថាមពល
- អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍន៍ សហគមន៍ជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនិងសប្បុរសជននានា និង
- ជំនួយឥតសំណងផ្សេងៗ។

គ.ជ.ប្រ.ថ. មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនីតិវិធីដូចមានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននូវមូលនិធិដែលបានមកពីដៃគូអភិវឌ្ឍន៍ និងប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែ ចេត្រ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខៈ ៤៧០ សជណ

**សូមជម្រាបជូន**

**ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត**

**កម្មវត្ថុ** : អំពីរបាយការណ៍បូកសរុបសកម្មភាពនិងលទ្ធផលការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន។

**យោង** : -សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៤ សណន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន

-សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលលេខ ០២ សណន ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ ស្តីពី ការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការបំពេញការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន។

-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាប **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបអំពីគោលការណ៍នៃការធ្វើរបាយការណ៍បូកសរុបសកម្មភាពនិងលទ្ធផលការងារ និងទម្រង់របាយការណ៍សម្រាប់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ធ្វើរបាយការណ៍បញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានទៀងទាត់ និងទាន់ពេលវេលា ដើម្បីបូកសរុបរាយការណ៍ជូនរាជរដ្ឋាភិបាល ដូចខាងក្រោម៖

១- ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងាររៀងរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំនីមួយៗ ផ្អែកលើទម្រង់របាយការណ៍ដូចមានជូនភ្ជាប់មកជាមួយនេះ។ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ក៏អាចប្រើប្រាស់ទម្រង់របាយការណ៍នេះ សម្រាប់ណែនាំដល់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ធ្វើរបាយការណ៍បូកសរុបផងដែរ។ របាយការណ៍បូកសរុបសកម្មភាពនិងលទ្ធផលការងារចុះមូលដ្ឋានរាជធានី ខេត្តត្រូវបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី ដូចខាងក្រោម៖

– របាយការណ៍ប្រចាំត្រីមាស ត្រូវបញ្ជូនមកយ៉ាងយូរត្រឹមថ្ងៃទី២៥ ខែទីបី នៃត្រីមាសនីមួយៗ

– របាយការណ៍ប្រចាំឆមាសទី១ មានរួមបញ្ចូលនូវលទ្ធផលការងារត្រីមាសទី២ ត្រូវបញ្ជូនមកយ៉ាងយូរត្រឹមថ្ងៃទី២៥ ខែទីប្រាំមួយ នៃឆមាសទី១

– របាយការណ៍ប្រចាំឆ្នាំ មានរួមបញ្ចូលនូវលទ្ធផលការងារត្រីមាសទី៤ ត្រូវបញ្ជូនមកយ៉ាងយូរត្រឹមថ្ងៃទី២៥ ខែធ្នូ នៃឆ្នាំនីមួយៗ។

២- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ត្រូវសហការ និងសម្របសម្រួល ឬណែនាំលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន រៀបចំរបាយការណ៍ដូចមានចែងក្នុងចំណុចទី១ខាងលើ ហើយត្រូវស្នើសុំការសម្រេចពីប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីបញ្ជូនមកទីស្ដីការគណៈរដ្ឋមន្ត្រី។ ទន្ទឹមនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវធ្វើការណែនាំដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីសហការ ឬដឹកនាំលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានដើម្បីធ្វើរបាយការណ៍បូកសរុបបញ្ជូនមករាជធានី ខេត្ត និងណែនាំឱ្យក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានឃុំ សង្កាត់ ធ្វើរបាយការណ៍ឱ្យទៀងទាត់ផ្ញើមកថ្នាក់ក្រុង ស្រុក ខណ្ឌសាមី ដើម្បីបូកសរុបវាយតម្លៃ និងតាមដានត្រួតពិនិត្យការងារ។

៣- ក្រៅពីរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ទីស្ដីការគណៈរដ្ឋមន្ត្រីអាចស្នើសុំឱ្យក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ធ្វើរបាយការណ៍តាមតម្រូវការចាំបាច់នៃការងារ។

៤- ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត អាចធ្វើសេចក្ដីរាយការណ៍សុំយោបល់ដឹកនាំដោយផ្ទាល់ពី **សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ទៅតាមតម្រូវការចាំបាច់នៃការងារ។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងសហការចាត់ចែងអនុវត្តតាមខ្លឹមសារដូចបានជម្រាបជូនខាងលើ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវសេចក្ដីគោរពរាប់អានអំពីខ្ញុំ។

ថ្ងៃ ចន្ទ ១៤ រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មេសា ឆ្នាំ២០២៤

**ជ.នាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**ចម្លងជូនៈ**

-គ្រប់ក្រសួង ស្ថាប័ន

-ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-រដ្ឋបាលរាជធានី ខេត្ត

-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន...**

**ទម្រង់របាយការណ៍**
**បូកសរុបលទ្ធផលការងារនៃក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន............**
**ប្រចាំ.............និងទិសដៅអនុវត្តបន្ត**

**១- អំពីស្ថានភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**

– ក្នុងត្រីមាស.../ឆមាស.../ឆ្នាំ... ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន... មានការប្រែប្រួលដូចខាងក្រោម៖
+ បំពេញបន្ថែមសមាសភាពសរុបចំនួន.....នាក់ (ស្រី.....នាក់) ក្នុងនោះ៖
- មន្ត្រីថ្នាក់ជាតិ ........នាក់ (ស្រី.........នាក់)
- មន្ត្រីថ្នាក់រាជធានី ខេត្ត ........នាក់ (ស្រី.........នាក់)
- មន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ ........នាក់ (ស្រី.........នាក់)
- មន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ ........នាក់ (ស្រី.........នាក់)។
+ ផ្ទេរចេញសរុបចំនួន .....នាក់ (ស្រី.....នាក់)
- មន្ត្រីថ្នាក់ជាតិ ........នាក់ (ស្រី.........នាក់)
- មន្ត្រីថ្នាក់រាជធានី ខេត្ត ........នាក់ (ស្រី.........នាក់)
- មន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ ........នាក់ (ស្រី.........នាក់)
- មន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ ........នាក់ (ស្រី.........នាក់)។

– ផ្អែកតាមស្ថានភាពខាងលើ គិតមកទល់..... ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន.... មានចំនួនសរុប .....នាក់ (ស្រី.....នាក់) ដូចមានតារាងឧបសម្ព័ន្ធ ភ្ជាប់មកជាមួយរបាយការណ៍នេះ ក្នុងនោះរួមមាន៖
- មន្ត្រីថ្នាក់ជាតិ សរុបចំនួន ........នាក់ (ស្រី.........នាក់)
+ មិនបានចាត់តាំងបន្តទៅថ្នាក់ក្រុង ស្រុក ខណ្ឌ ឬឃុំ សង្កាត់ ចំនួន...នាក់ (ស្រី...នាក់)
- មន្ត្រីថ្នាក់រាជធានី ខេត្ត សរុបចំនួន ........នាក់ (ស្រី.........នាក់)
+ មិនបានចាត់តាំងបន្តទៅថ្នាក់ក្រុង ស្រុក ខណ្ឌ ឬឃុំ សង្កាត់ ចំនួន...នាក់ (ស្រី...នាក់)
- មន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ សរុបចំនួន ........នាក់ (ស្រី.........នាក់)
+ មិនបានចាត់តាំងបន្តទៅថ្នាក់ឃុំ សង្កាត់ ភូមិ ចំនួន...នាក់ (ស្រី...នាក់)
- មន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ សរុបចំនួន ........នាក់ (ស្រី.........នាក់)
+ មិនបានចាត់តាំងបន្តទៅតាមភូមិ ចំនួន...នាក់ (ស្រី...នាក់)។

***កត់សម្គាល់៖*** *កន្លងមក រាជរដ្ឋាភិបាលបានចាត់តាំងថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់នៃក្រសួង ស្ថាប័ន ចូលរួមក្នុងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត។ ផ្អែកលើការចាត់តាំងនេះ ក្រុមការងារ*

រាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត និងបានបន្តចាត់តាំងសមាសភាពក្នុងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ចូលរួមក្នុងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក ខណ្ឌ ហើយក៏បានបញ្ចូលបន្ថែមនូវសមាសភាពជាថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទនៃក្រសួង ស្ថាប័នផងដែរ។ ជាមួយនេះ ក្រុមការងារចុះរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ក៏បានបន្តចាត់តាំងសមាសភាពក្នុងក្រុមការងារចុះរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ចូលរួមក្នុងក្រុមការងារចុះឃុំ សង្កាត់ និងបានបញ្ចូលនូវសមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួង ស្ថាប័នបន្ថែមទៀត។

ស្ថានភាពនេះនឹងធ្វើឱ្យការបូកសរុបចំនួនសមាសភាពក្រុមការងារចុះរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ភូមិ ទូទាំងប្រទេស ដោយមិនបានដកឈ្មោះស្ទួន នោះធ្វើឱ្យចំនួនសរុបក្រុមការងារកើនលើសពីចំនួនជាក់ស្តែង។ ករណីនេះ ទីស្តីការគណៈរដ្ឋមន្ត្រីបានរៀបចំនូវតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយរបាយការណ៍នេះ ដើម្បីលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលមូលដ្ឋាននៃថ្នាក់រដ្ឋបាលនីមួយៗ ធ្វើការបូកសរុប ក្នុងនោះ រួមមាន៖

- តារាងឧបសម្ព័ន្ធទី១ សម្រាប់រាជធានី ខេត្ត
- តារាងឧបសម្ព័ន្ធទី២ សម្រាប់ក្រុង ស្រុក ខណ្ឌ
- តារាងឧបសម្ព័ន្ធទី៣ សម្រាប់ឃុំ សង្កាត់។

ក្នុងតារាងឧបសម្ព័ន្ធនីមួយៗខាងលើ មានកំណត់អំពីរូបមន្តគណនា និងទិន្នន័យតម្រូវឱ្យលេខាធិការដ្ឋានធ្វើការបញ្ចូល។

## ២- ការចូលរួមគាំទ្រការអនុវត្តកម្មវិធីគោលនយោបាយអាទិភាព និងវិធានការនានារបស់រាជរដ្ឋាភិបាល

- របាយការណ៍អំពីសកម្មភាពសំខាន់ៗដែលក្រុមការងារបានចូលរួមគាំទ្រការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពទាំង៦ និងវិធានការគន្លឹះទាំង៥ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា រួមទាំងការគាំទ្រ និងជំរុញការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការផ្តល់សេវាជូនប្រជាពលរដ្ឋតាមយន្តការច្រកចេញចូលតែមួយ...។ល។
- របាយការណ៍ត្រូវធ្វើការវាយតម្លៃអំពីសមិទ្ធផល និងបញ្ហាប្រឈមនៃការងារនីមួយៗ ដោយត្រូវស្រាវជ្រាវ ឆ្លុះបញ្ចាំងនូវទិន្នន័យសំខាន់ៗដើម្បីងាយស្រួលបូកសរុប តាមដាន និងវាយតម្លៃ។

## ៣- សកម្មភាពសំខាន់ៗដែលក្រុមការងាររាជរដ្ឋាភិបាលបានអនុវត្ត

៣.១- ការរៀបចំកិច្ចប្រជុំ

**កត់សម្គាល់៖** ក្នុងការចុះទៅបំពេញការងារនៅមូលដ្ឋាន ក្រុមការងារតែងតែប្រជុំជាមួយមន្ត្រី អាជ្ញាធរ មន្ទីរ អង្គភាពពាក់ព័ន្ធនៅថ្នាក់ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត ដើម្បីវាយតម្លៃអំពីចេនាសម្ព័ន្ធ ស្ថានភាពមន្ត្រី និងអនុវត្តតួនាទីភារកិច្ចរបស់មន្ត្រី ដើម្បីពង្រឹងស្ថាប័ននានានៅមូលដ្ឋាន ឬការប្រជុំភ្ជាប់សភាពការណ៍ទូទៅនៅមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ឬជាការប្រជុំតាមដាន ពិនិត្យពិភាក្សា វាយតម្លៃ សកម្មភាពលទ្ធផលការងារ និងបញ្ហាប្រឈមនានារបស់ក្រុមការងារក្នុងការចុះបំពេញការងារតាមមូលដ្ឋាន និងការប្រជុំផ្សេងៗទៀត។ (ស្នើរាយការណ៍កិច្ចប្រជុំសំខាន់ៗ និងលទ្ធផលដែលសម្រេចបាន)។

៣.២- ការរៀបចំវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋ ដើម្បីដោះស្រាយឆ្លើយតបបញ្ហាប្រឈម សំណូមពរ និងកង្វល់របស់ប្រជាពលរដ្ឋ

៣.៣- ការចូលរួមសកម្មភាពនានានៅមូលដ្ឋានដូចជា ការចូលរួមទិវាបុណ្យជាតិនិងអន្តរជាតិ ពិធីសម្ពោធសមិទ្ធផល ពិធីបុណ្យសាសនា ការប្រកួតកីឡា ការដាំដើមឈើ ការដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តជួយព្យាបាលជំងឺជូនប្រជាពលរដ្ឋ សកម្មភាពមនុស្សធម៌ និងពិធីនានាជាច្រើនទៀត...។ល។

៣.៤. ការចូលរួមឧបត្ថម្ភគ្រឿងឧបភោគ សម្ភារ និងថវិកាដល់មូលដ្ឋាន ដូចជា ការជួយឧបត្ថម្ភស្បៀងគ្រឿងឧបភោគបរិភោគដល់ប្រជាពលរដ្ឋជួបគ្រោះធម្មជាតិឬគ្រោះថ្នាក់នានា ការជួយដល់ប្រជាពលរដ្ឋក្រីក្រ ក្រុមជនងាយរងគ្រោះនានា...។ល។

៣.៥- ការចុះជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋ (តាមខ្នងផ្ទះ តាមទីផ្សារ តាមការដ្ឋានការងារ...)

<table>
<tr><th rowspan="3">សកម្មភាព</th><th rowspan="3">ចំនួន (ដង)</th><th colspan="4">សមាសភាពក្រុមការងារ</th><th colspan="2">ប្រជាពលរដ្ឋ</th></tr>
<tr><th colspan="2">ថ្នាក់ជាតិ</th><th colspan="2">ថ្នាក់ក្រោមជាតិ</th><th rowspan="2">សរុប</th><th rowspan="2">ស្រី</th></tr>
<tr><th>សរុប</th><th>ស្រី</th><th>សរុប</th><th>ស្រី</th></tr>
<tr><td>ការរៀបចំកិច្ចប្រជុំ</td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>ការរៀបចំវេទិកាសាធារណៈ</td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>ការចូលរួមសកម្មភាពនានានៅមូលដ្ឋាន</td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>ការឧបត្ថម្ភគ្រឿងឧបភោគបរិភោគ ចុះជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋ</td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>សរុប</td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
</table>

## ៤- ការចូលរួមកសាងសមិទ្ធផលសង្គមនៅមូលដ្ឋាន

– សមិទ្ធផលសង្គមដែលកសាងដោយធនធានផ្ទាល់របស់ក្រុមការងារ។

– សមិទ្ធផលសង្គមដែលក្រុមការងារកៀរគរពីសប្បុរសជន និងពីប្រភពស្របច្បាប់នានា។

## ៥-លទ្ធផលនៃការរៀបចំវេទិកាសាធារណៈ

៥.១-តារាងបញ្ហាប្រឈម និងដំណោះស្រាយ

| ប្រភេទ | ចំនួនករណី | ភាគរយ % | បានដោះស្រាយ (%) | កំពុងដោះស្រាយ (%) | មិនទាន់បានដោះស្រាយ (%) | ស្នើទៅថ្នាក់ជាតិ (%) | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| សំណើ/សំណូមពរ | | | | | | | |
| បញ្ហាប្រឈម | | | | | | | |
| ទំនាស់ ឬការតវ៉ានានា | | | | | | | |

៥.២-តារាងប្រភេទនៃដំណោះស្រាយ តាមវិស័យគិតជាភាគរយ

| ល.រ | បញ្ហាប្រឈម និងដំណោះស្រាយ តាមវិស័យ | សរុបករណី | ភាគរយ % | បាន ដោះស្រាយ % | កំពុង ដោះស្រាយ % | មិនទាន់បាន ដោះស្រាយ % | ផ្ញើទៅថ្នាក់ជាតិ % |
|---|---|---|---|---|---|---|---|
| ១ | វិស័យអប់រំ យុវជន និងកីឡា | | | | | | |
| ២ | វិស័យសុខាភិបាល | | | | | | |
| ៣ | វិស័យការងារ | | | | | | |
| ៤ | វិស័យសង្គមកិច្ច | | | | | | |
| ៥ | វិស័យសេដ្ឋកិច្ច | | | | | | |
| ៦ | វិស័យកសិកម្ម ជលផល និងព្រៃឈើ | | | | | | |
| ៧ | វិស័យអភិវឌ្ឍន៍ជនបទ | | | | | | |
| ៨ | វិស័យធនធានទឹក និងឧតុនិយម | | | | | | |
| ៩ | វិស័យដីធ្លី | | | | | | |
| ១០ | វិស័យអគ្គិសនី | | | | | | |
| ១១ | វិស័យសន្តិសុខ សណ្តាប់ធ្នាប់ | | | | | | |
| ១២ | ការផ្តល់សេវាគ្រប់ប្រភេទ និងអភិបាលកិច្ច | | | | | | |
| ១៣ | ទឹកស្អាត និងអនាម័យជនបទ | | | | | | |
| ១៤ | វិស័យសាធារណការ និងដឹកជញ្ជូន | | | | | | |
| ១៥ | វិស័យបរិស្ថាន | | | | | | |
| ១៦ | វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ | | | | | | |
| ១៧ | វិស័យរ៉ែ និងថាមពល | | | | | | |
| ១៨ | វិស័យពាណិជ្ជកម្ម | | | | | | |
| ១៩ | វិស័យទេសចរណ៍ | | | | | | |
| ២០ | វិស័យធម្មការ និងសាសនា | | | | | | |

***កត់សម្គាល់៖***

- *សំណើ/សំណូមពរ៖ គឺជាសំណើសុំ ឬសំណូមពរនានាដែលប្រជាពលរដ្ឋ មន្ត្រី អាជ្ញាធរមូលដ្ឋានបានស្នើសុំ ដូចជាការស្នើសុំផ្លូវថ្នល់ ប្រឡាយទឹក សាលារៀន...។ល។*
- *បញ្ហាប្រឈម៖ គឺជាកង្វល់របស់ប្រជាពលរដ្ឋនៅមូលដ្ឋានពាក់ព័ន្ធជីវភាពរស់នៅប្រចាំថ្ងៃ។ ឧទាហរណ៍៖ បញ្ហាគ្រឿងញៀន ល្បែងស៊ីសង គ្រោះថ្នាក់ចរាចរណ៍ ជាអាទិ៍។*
- *ទំនាស់៖ គឺជាជម្លោះ ឬការទាមទារតវ៉ានានារបស់ប្រជាជននៅមូលដ្ឋាន។*

៦-បញ្ហាប្រឈមក្នុងការបំពេញការងាររបស់ក្រុមការងារ
៧-សំណូមពរ
៨-សេចក្ដីសន្និដ្ឋាន
៩-ទិសដៅសម្រាប់អនុវត្តបន្ត

ថ្ងៃ ខែ ឆ្នាំ ..ស័ក ព.ស.២៥៦..
.......... ថ្ងៃទី ខែ ឆ្នាំ២០២..
**អភិបាល...និងជាអនុប្រធានអចិន្ត្រៃយ៍**

បានឃើញ និងឯកភាព
ថ្ងៃ ខែ ឆ្នាំ ..ស័ក ព.ស.២៥៦..
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២..
**ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន...**

### តារាងឧបសម្ព័ន្ធទី១៖ ចំនួនសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត...

I. **ថ្នាក់រាជធានី ខេត្ត...** *(ស្រង់ចំនួនក្រុមការងារផ្អែកតាមសេចក្ដីសម្រេច)*

| | ឈ្មោះរាជធានី ខេត្ត | សមាសភាពក្រុមការងារ | | | | | | | | | | | | | | | | ចំនួនក្រុមការងាររាជធានី ខេត្ត | | ចំនួនក្រុមការងារមិនពង្រាយទៅថ្នាក់ក្រុង ស្រុក ខណ្ឌ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មន្ត្រីថ្នាក់ជាតិ | | | | មន្ត្រីថ្នាក់រាជធានី ខេត្ត | | | | មន្ត្រីក្រុង ស្រុក ខណ្ឌ | | | | មន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ | | | | | | | | |
| | | ចំនួន | | មិនពង្រាយទៅថ្នាក់ក្រុង ស្រុក ខណ្ឌ | | ចំនួន | | មិនពង្រាយទៅថ្នាក់ក្រុង ស្រុក ខណ្ឌ | | ចំនួន | | មិនពង្រាយទៅថ្នាក់ក្រុង ស្រុក ខណ្ឌ | | ចំនួន | | មិនពង្រាយទៅថ្នាក់ក្រុង ស្រុក ខណ្ឌ | | | | | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| | A | B | C | D | E | F | G | H | I | J | K | L | M | N | O | P | Q | R | S | T=D+H+L+P | U=E+I+M+Q | V |
| A1 | រាជធានី ខេត្ត... | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |

II. **ថ្នាក់ក្រុង ស្រុក ខណ្ឌ...** *(ស្រង់ចំនួនក្នុង (III) នៃតារាងឧបសម្ព័ន្ធទី២ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក ខណ្ឌ)*

| | ឈ្មោះក្រុង ស្រុក ខណ្ឌ | សមាសភាពក្រុមការងារ | | | | | | | | ចំនួន | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មន្ត្រីថ្នាក់ជាតិ | | មន្ត្រីថ្នាក់រាជធានី ខេត្ត | | មន្ត្រីក្រុង ស្រុក ខណ្ឌ | | មន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ | | សរុប | ស្រី | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | | | |
| | A | B | C | D | E | F | G | H | I | J | K | L |
| B1 | ក្រុង .. | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B2 | ស្រុក . | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B3 | ខណ្ឌ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B4 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B5 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B6 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B7 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B8 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B9 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B10 | សរុប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |

III. **ចំនួនក្រុមការងារថ្នាក់រាជធានី ខេត្ត ដោយមិនរាប់ឈ្មោះស្ទួននៅតាមបណ្ដាក្រុង ស្រុក ខណ្ឌ**

**ចំនួនសរុបថ្នាក់រាជធានី ខេត្ត** 0 **នាក់** **ស្រី** 0 **នាក់**

ចំនួនសរុបមន្ត្រីថ្នាក់ជាតិ 0 នាក់ ស្រី 0 នាក់

ចំនួនសរុបមន្ត្រីថ្នាក់រាជធានី ខេត្ត 0 នាក់ ស្រី 0 នាក់

ចំនួនសរុបមន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ 0 នាក់ ស្រី 0 នាក់

ចំនួនសរុបមន្ត្រីតាមឃុំ សង្កាត់ ភូមិ 0 នាក់ ស្រី 0 នាក់

បានឃើញ និងឯកភាព

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦...

ក្រុង ស្រុក ខណ្ឌ... ថ្ងៃទី ខែ ឆ្នាំ២០២...

**ប្រធានលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦...

ក្រុង ស្រុក ខណ្ឌ... ថ្ងៃទី ខែ ឆ្នាំ២០២...

**មន្ត្រីទទួលបន្ទុករៀបចំ**

**របៀបគណនាចំនួនក្រុមការងារឆ្នាំឲរាជធានី ខេត្ត**

(ជាចំនួនមិនរាប់ឈ្មោះស្ទួននៅតាមបណ្ដាក្រុង ស្រុក ខណ្ឌ)

| | |
|---|---|
| ចំនួនសរុបទូទាំងស្រុក | = [R(A1)+J(B10)] - [R(A1)-T(A1)] |
| ស្រី | = [S(A1)+K(B10)] - [S(A1)-U(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់ជាតិ | = [B(A1)+B(B10)] - [B(A1)-D(A1)] |
| ស្រី | = [C(A1)+C(B10)] - [C(A1)-E(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់រាជធានី ខេត្ត | = [F(A1)+D(B10)] - [F(A1)-H(A1)] |
| ស្រី | = [G(A1)+E(B10)] - [G(A1)-I(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ | = [J(A1)+F(B10)] - [J(A1)-L(A1)] |
| ស្រី | = [K(A1)+G(B10)] - [K(A1)-M(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ | = [N(A1)+H(B10)] - [N(A1)-P(A1)] |
| ស្រី | = [O(A1)+I(B10)] - [O(A1)-Q(A1)] |

<u>សម្គាល់៖</u> អក្សរ B10 នៅក្នុងរូបមន្តខាងលើនេះអាចប្រែប្រួលទៅតាមចំនួនក្រុង ស្រុក ខណ្ឌ ជាក់ស្តែងនៅក្នុងរាជធានី ខេត្ត សាមី

### តារាងឧបសម្ព័ន្ធទី២៖ ចំនួនសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក ខណ្ឌ...

I. ថ្នាក់ក្រុង ស្រុក ខណ្ឌ... *(ស្រង់ចំនួនក្រុមការងារផ្អែកតាមសេចក្តីសម្រេច)*

| ឈ្មោះក្រុង ស្រុក ខណ្ឌ | | សមាសភាពក្រុមការងារ | | | | | | | | | | | | | | | | ចំនួនក្រុមការងារក្រុង ស្រុក ខណ្ឌ | | ចំនួនក្រុមការងារមិនពង្រាយទៅថ្នាក់ឃុំ សង្កាត់ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មន្ត្រីថ្នាក់ជាតិ | | | | មន្ត្រីថ្នាក់រាជធានី ខេត្ត | | | | មន្ត្រីក្រុង ស្រុក ខណ្ឌ | | | | មន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ | | | | | | | | |
| | | ចំនួន | | មិនពង្រាយទៅថ្នាក់ឃុំ សង្កាត់ | | ចំនួន | | មិនពង្រាយទៅថ្នាក់ឃុំ សង្កាត់ | | ចំនួន | | មិនពង្រាយទៅថ្នាក់ឃុំ សង្កាត់ | | ចំនួន | | មិនពង្រាយទៅថ្នាក់ឃុំ សង្កាត់ | | | | | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| | A | B | C | D | E | F | G | H | I | J | K | L | M | N | O | P | Q | R | S | T=D+H+L+P | U=E+I+M+Q | V |
| A1 | ក្រុង ស្រុក ខណ្ឌ... | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |

II. ថ្នាក់ឃុំ សង្កាត់... *(ស្រង់ចំនួនក្នុង (III) នៃតារាងឧបសម្ព័ន្ធទី៣ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានឃុំ សង្កាត់)*

| ឈ្មោះឃុំ សង្កាត់ | | សមាសភាពក្រុមការងារ | | | | | | | | ចំនួន | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មន្ត្រីថ្នាក់ជាតិ | | មន្ត្រីថ្នាក់រាជធានី ខេត្ត | | មន្ត្រីក្រុង ស្រុក ខណ្ឌ | | មន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ | | សរុប | ស្រី | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | | | |
| | A | B | C | D | E | F | G | H | I | J | K | L |
| B1 | ឃុំ... | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B2 | សង្កាត់... | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B3 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B4 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B5 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B6 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B7 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B8 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B9 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B10 | សរុប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |

III. ចំនួនក្រុមការងារទូទាំងក្រុង ស្រុក ខណ្ឌ ដោយមិនរាប់ឈ្មោះស្ទួននៅតាមបណ្តាឃុំ សង្កាត់ ភូមិ

| | | | | | |
|---|---|---|---|---|---|
| **ចំនួនសរុបទូទាំងក្រុង ស្រុក ខណ្ឌ** | 0 | **នាក់** | **ស្រី** | 0 | **នាក់** |
| ចំនួនសរុបមន្ត្រីថ្នាក់ជាតិ | 0 | នាក់ | ស្រី | 0 | នាក់ |
| ចំនួនសរុបមន្ត្រីថ្នាក់រាជធានី ខេត្ត | 0 | នាក់ | ស្រី | 0 | នាក់ |
| ចំនួនសរុបមន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ | 0 | នាក់ | ស្រី | 0 | នាក់ |
| ចំនួនសរុបមន្ត្រីតាមឃុំ សង្កាត់ ភូមិ | 0 | នាក់ | ស្រី | 0 | នាក់ |

បានឃើញ និងឯកភាព

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦...

ក្រុង ស្រុក ខណ្ឌ... ថ្ងៃទី ខែ ឆ្នាំ២០២...

**ប្រធានលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦...

ក្រុង ស្រុក ខណ្ឌ... ថ្ងៃទី ខែ ឆ្នាំ២០២...

**មន្ត្រីទទួលបន្ទុករៀបចំ**

**របៀបគណនាចំនួនក្រុមការងារទូទាំងក្រុង ស្រុក ខណ្ឌ**

(ជាចំនួនមិនរាប់ឈ្មោះស្ទួននៅតាមបណ្តាឃុំ សង្កាត់ ភូមិ)

| | |
|---|---|
| ចំនួនសរុបទូទាំងស្រុក | = [R(A1)+J(B10)] - [R(A1)-T(A1)] |
| ស្រី | = [S(A1)+K(B10)] - [S(A1)-U(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់ជាតិ | = [B(A1)+B(B10)] - [B(A1)-D(A1)] |
| ស្រី | = [C(A1)+C(B10)] - [C(A1)-E(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់រាជធានី ខេត្ត | = [F(A1)+D(B10)] - [F(A1)-H(A1)] |
| ស្រី | = [G(A1)+E(B10)] - [G(A1)-I(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ | = [J(A1)+F(B10)] - [J(A1)-L(A1)] |
| ស្រី | = [K(A1)+G(B10)] - [K(A1)-M(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ | = [N(A1)+H(B10)] - [N(A1)-P(A1)] |
| ស្រី | = [O(A1)+I(B10)] - [O(A1)-Q(A1)] |

សម្គាល់៖ អក្សរ B10 នៅក្នុងរូបមន្តខាងលើនេះអាចប្រែប្រួលទៅតាមចំនួនឃុំ សង្កាត់ ជាក់ស្តែងនៅក្នុងក្រុង ស្រុក ខណ្ឌ សាមី

## តារាងឧបសម្ព័ន្ធទី៣៖ ចំនួនសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានឃុំ សង្កាត់...

I. ថ្នាក់ឃុំ សង្កាត់... *(ស្រង់ចំនួនក្រុមការងារផ្អែកតាមសេចក្ដីសម្រេច)*

| | ឈ្មោះឃុំ សង្កាត់ | សមាសភាពក្រុមការងារ | | | | | | | | | | | | | | | | ចំនួនក្រុមការងារឃុំ សង្កាត់ | | ចំនួនក្រុមការងារមិនពង្រាយទៅតាមភូមិ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មន្ត្រីថ្នាក់ជាតិ | | | | មន្ត្រីថ្នាក់រាជធានី ខេត្ត | | | | មន្ត្រីក្រុង ស្រុក ខណ្ឌ | | | | មន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ | | | | | | | | |
| | | ចំនួន | | មិនពង្រាយទៅតាមភូមិ | | ចំនួន | | មិនពង្រាយទៅតាមភូមិ | | ចំនួន | | មិនពង្រាយទៅតាមភូមិ | | ចំនួន | | មិនពង្រាយទៅតាមភូមិ | | | | | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| | A | B | C | D | E | F | G | H | I | J | K | L | M | N | O | P | Q | R | S | T=D+H+L+P | U=E+I+M+Q | V |
| A1 | ឃុំ សង្កាត់... | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |

II. ភូមិ... *(ស្រង់ចំនួនក្រុមការងារក្រោមភូមិ ផ្អែកតាមសេចក្ដីសម្រេច)*

| | ឈ្មោះភូមិ | សមាសភាពក្រុមការងារ | | | | | | | | ចំនួន | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មន្ត្រីថ្នាក់ជាតិ | | មន្ត្រីថ្នាក់រាជធានី ខេត្ត | | មន្ត្រីក្រុង ស្រុក ខណ្ឌ | | មន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ | | សរុប | ស្រី | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | | | |
| | A | B | C | D | E | F | G | H | I | J | K | L |
| B1 | ភូមិ... | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B2 | ភូមិ... | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B3 | ភូមិ... | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B4 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B5 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B6 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B7 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B8 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B9 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| B10 | សរុប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |

**III. ចំនួនក្រុមការងារឆ្នាំឃុំ ដោយមិនរាប់ឈ្មោះស្ទួននៅតាមបណ្ដាភូមិ**

| | | | | | |
|---|---|---|---|---|---|
| **ចំនួនសរុបឆ្នាំឃុំ** | 0 | **នាក់** | **ស្រី** | 0 | **នាក់** |
| ចំនួនសរុបមន្ត្រីថ្នាក់ជាតិ | 0 | នាក់ | ស្រី | 0 | នាក់ |
| ចំនួនសរុបមន្ត្រីថ្នាក់រាជធានី ខេត្ត | 0 | នាក់ | ស្រី | 0 | នាក់ |
| ចំនួនសរុបមន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ | 0 | នាក់ | ស្រី | 0 | នាក់ |
| ចំនួនសរុបមន្ត្រីតាមឃុំ សង្កាត់ ភូមិ | 0 | នាក់ | ស្រី | 0 | នាក់ |

បានឃើញ និងឯកភាព

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦...

ក្រុង ស្រុក ខណ្ឌ... ថ្ងៃទី ខែ ឆ្នាំ២០២...

**ប្រធានលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦...

ក្រុង ស្រុក ខណ្ឌ... ថ្ងៃទី ខែ ឆ្នាំ២០២...

**មន្ត្រីទទួលបន្ទុករៀបចំ**

**របៀបគណនាចំនួនក្រុមការងារឆ្នាំឃុំ សង្កាត់**

(ជាចំនួនមិនរាប់ឈ្មោះស្ទួននៅតាមបណ្ដាភូមិ)

| | | |
|---|---|---|
| ចំនួនសរុបទូទាំងស្រុក | = | [R(A1)+J(B10)] - [R(A1)-T(A1)] |
| ស្រី | = | [S(A1)+K(B10)] - [S(A1)-U(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់ជាតិ | = | [B(A1)+B(B10)] - [B(A1)-D(A1)] |
| ស្រី | = | [C(A1)+C(B10)] - [C(A1)-E(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់រាជធានី ខេត្ត | = | [F(A1)+D(B10)] - [F(A1)-H(A1)] |
| ស្រី | = | [G(A1)+E(B10)] - [G(A1)-I(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ | = | [J(A1)+F(B10)] - [J(A1)-L(A1)] |
| ស្រី | = | [K(A1)+G(B10)] - [K(A1)-M(A1)] |
| ចំនួនសរុបមន្ត្រីថ្នាក់ឃុំ សង្កាត់ ភូមិ | = | [N(A1)+H(B10)] - [N(A1)-P(A1)] |
| ស្រី | = | [O(A1)+I(B10)] - [O(A1)-Q(A1)] |

<u>សម្គាល់៖</u> អក្សរ B10 នៅក្នុងរូបមន្តខាងលើនេះអាចប្រែប្រួលទៅតាមចំនួនភូមិជាក់ស្ដែងនៅក្នុងឃុំសាមី